ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ២១/០៩ — យ៉ុង វ៉ា ទី២**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **ឈឺវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូ អិលធីឌី ទី២**

អាសយដ្ឋាន : ភូមិថ្មី ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៩១០ ៥៦៦ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក NG MIN CHUAN | Office Manager |
| ២- លោក សោម អ៊ុយពិសី | រដ្ឋបាល |
| ៣- លោកស្រី លី មួយឆេង | រដ្ឋបាល |

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - **សហព័ន្ធសហជីពកម្មករកម្ពុជា**

- **សហជីពកម្មករនិយោជិតនៃរោងចក្រ យ៉ុង វ៉ា ទី២**

អាសយដ្ឋាន : ផ្ទះលេខ ៣០ សេ ផ្លូវលេខ ៣៧១ ភូមិ ត្រពាំងឈូក សង្កាត់ ទឹកថ្លា ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១១ ៦៨៥ ៨២៦ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក សេង ម៉េងហុង មន្ត្រីសហព័ន្ធ CLUF

២- លោក ភិន ធូក ប្រធានសហជីពកម្មករនិយោជិត យ៉ុង វ៉ា ទី២

៣- លោក កែវ សុទ្ធា ប្រធានសហជីពកម្មករនិយោជិត យ៉ុង វ៉ា ទី៤

៤- លោក មិន វុទ្ធី អនុប្រធានសហជីពកម្មករនិយោជិត យ៉ុង វ៉ា ទី២

៥- លោក សៅ សំបូរវាសនា អនុប្រធានសហជីពកម្មករនិយោជិត យ៉ុង វ៉ា ទី៤

៦- លោក សេង វេច្ឆនា លេខាធិការសហជីពកម្មករនិយោជិត យ៉ុង វ៉ា ទី២

៧- លោក ប្រាក់ ចាន់ថន លេខាធិការសហជីពកម្មករនិយោជិត យ៉ុង វ៉ា ទី៤

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករសុំឱ្យក្រុមហ៊ុនផ្តល់ឯកសារជាកិច្ចសន្យាការងារមួយច្បាប់ជូនសាមីកម្មករ ។ ភាគីក្រុមហ៊ុនថតចម្លងជូនសាមីកម្មករណា ដែលមកទាក់ទងផ្ទាល់ចំពោះឯកសារកិច្ចសន្យាការងារនោះ ។

២- ភាគីកម្មករសុំឱ្យក្រុមហ៊ុនរៀបចំបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកសារជាថ្មី ព្រោះប្រតិភូបុគ្គលិកចាស់បានផុតអាណត្តិជាង ០៣ ឆ្នាំ កន្លងមកហើយ (យ៉ុង វ៉ា ទី២) ។ ក្រុមហ៊ុននឹងផ្តល់ដំណឹងជូនកម្មករវិញ នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ។

៣- ភាគីកម្មករសុំឱ្យក្រុមហ៊ុនសាងសង់រោងបាយបន្ថែមជូនប្រចាំអាគារទី៣ និងទី៤ ក្នុងបរិវេណរោងចក្រ យ៉ុង វ៉ា ដែលបានធ្លាប់សន្យាពីមុនមក ។ ភាគីក្រុមហ៊ុនមិនឯកភាព ពីព្រោះក្រុមហ៊ុនជួបប្រទះបញ្ហាហិរញ្ញវត្ថុដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក ។

៤- កម្មករទាមទារឱ្យក្រុមហ៊ុនទទួលយកសំបុត្រពេទ្យការងារក្បាលថ្នល់ និងមណ្ឌលសុខភាពមន្ទីរពេទ្យដទៃទៀត ដែលជាពេទ្យរដ្ឋនៅពេលកម្មករឈប់សំរាកដោយជំងឺ សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ការងារទៀតទាត់ជូនកម្មករដោយពុំចាំបាច់មានលិខិតអនុញ្ញាតពីរដ្ឋបាល និងគ្រូពេទ្យប្រចាំក្រុមហ៊ុនជាមុន ។ ក្រុមហ៊ុនមិនឯកភាព ។

៥- កម្មករសុំឱ្យក្រុមហ៊ុនដកពាក្យបណ្តឹងថ្នាក់ដឹកនាំសហជីពកម្មករកម្ពុជា ចេញពីតុលាការសាលាដំបូងខេត្តកណ្តាលដោយឥតលក្ខខណ្ឌ ពីព្រោះថ្នាក់ដឹកនាំសហជីពកម្មករកម្ពុជា គ្រាន់តែជាអ្នកជួយសំរបសំរួលដោះស្រាយរកប្រយោជន៍ស្របច្បាប់ជូនកម្មករប៉ុណ្ណោះ ។ ភាគីក្រុមហ៊ុនមិនឯកភាព ។

៦- កម្មករទាមទារឱ្យក្រុមហ៊ុនគិត និងទូទាត់ប្រាក់ឈប់សំរាកប្រចាំឆ្នាំជូនយើងខ្ញុំជាកម្មករ ដោយគិតជាមធ្យមភាគ ។ ភាគីក្រុមហ៊ុនមិនឯកភាព ។

៧- កម្មករនិយោជិតសុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលជូនក្នុងកំឡុងពេលពីថ្ងៃទី ០៧ រហូតដល់ថ្ងៃទី ០៩ នៃខែបន្ទាប់ ។ ភាគីក្រុមហ៊ុនមិនឯកភាព ។

៨- ភាគីកម្មករសុំឱ្យក្រុមហ៊ុនអធ្យាស្រ័យដល់កម្មករ បើកម្មករណាម្នាក់ដែលបានប្រព្រឹត្តកំហុសធ្ងន់ ដូចជាបានលួចខោអាវរោងចក្រ មួយ ឬ ពីរ របស់ក្រុមហ៊ុន គួរតែបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនោះបានហើយ ដោយពុំចាំបាច់ប្តឹង និងចាប់កម្មករនោះដាក់គុក ដាក់ច្រវ៉ាក់ឡើយ ។ ភាគីក្រុមហ៊ុនមិនឯកភាព ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧ ) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៧៦/០៧ កកបវ/ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួមដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០៦៥/០៩ កប/កណ. ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ (វេលាម៉ោង ០៩:៣០ នាទី ព្រឹក)

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៩ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលបណ្តឹងរបស់ភាគីកម្មករនិយោជិតរបស់សហព័ន្ធសហជីពកម្មករកម្ពុជា ដែលមានចំណុចវិវាទចំនួន ១៣ ចំណុច ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើ

ការដោះស្រាយវិវាទការងារនេះ នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ដោយបានទទួលលទ្ធផលសះជាចំនួន ០៥ ចំណុច លើការទាមទារទាំងអស់ចំនួន ១៣ ចំណុច។ ចំណុចមិនសះជាចំនួន ០៨ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីសហជីពកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៨ ចំណុចនេះ នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ (វេលាម៉ោង ០៩:៣០ នាទី ព្រឹក)។ ភាគីទាំងពីរ មានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០៨ ចំណុចនេះ។ ជាលទ្ធផល ភាគីសហជីព កម្មករនិយោជិតបានសុំស្នើដកចំណុចទី០៤ ទី០៥ ទី០៦ និង ទី០៨ ចេញពីការទាមទារក្នុងសំណុំរឿងនេះ ហើយភាគីទាំងពីរបានធ្វើការចរចារទទួលបានលទ្ធផលសះជាចំនួន ០៣ ចំណុចបន្ថែមទៀត គឺចំណុចទី០១ ទី០២ និង ទី០៧។ នៅសល់ចំណុចមិនសះជាចំនួន ០១ ចំណុច គឺ ចំណុចវិវាទទី៣។

ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចវិវាទមិនសះជានេះ ដោយផ្អែកលើភស្តុតាង និង ហេតុផល ដូចខាងក្រោមៈ

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន យ៉ុង វ៉ា ទី២ ចុះបញ្ជីលេខ ០០៨/០៦ កបវ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងក្រុមហ៊ុន យ៉ុង វ៉ា លេខ ៩៨១ ពណ.នតក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៨។

៣- បញ្ជីរាយនាមកម្មករទទួលកិច្ចសន្យាការងាររបស់ក្រុមហ៊ុន យ៉ុង វ៉ា ។

៤- លិខិតរបស់ក្រុមហ៊ុន យ៉ុង វ៉ា លេខ ៣៣៥/០៨ យវ គោរពជូនប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ស្តីពីសំណើសុំដោះស្រាយតាមផ្លូវច្បាប់ក្នុងការបោះឆ្នោតជ្រើសរើសតំណាងកម្មករប្រចាំក្រុមហ៊ុន យ៉ុង វ៉ា ទី២ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៨។

៥- កំណត់ហេតុនៃការប្រជុំស្តីពីការបោះឆ្នោតជ្រើសរើសតំណាងកម្មករ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៨។

៦- សេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ និងឈ្មោះសំណុំរឿង ៥៤/០៧-យ៉ុង វ៉ា ទី១ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧។

៧- ប្រកាសផ្ទៃក្នុងលេខ ៤០៥/០៨ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨។

៨- លិខិតប្តឹងជំទាស់នឹងសេចក្តីបង្គាប់អាជ្ញាកណ្តាលសំណុំរឿងលេខ ៧២/០៨-យ៉ុង វ៉ា ទី២ របស់ក្រុមហ៊ុន យ៉ុង វ៉ា ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៨។

៩- សេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ និងឈ្មោះសំណុំរឿង ៧២/០៨-យ៉ុង វ៉ា ទី២ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៨។

១០- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន យ៉ុង វ៉ា ជូនលោក Ng Min Chuan ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៩ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្មកនិយោជិត នៃរោងចក្រ យ៉ុង វ៉ា ទី២ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៧ ។

២- លិខិតអនុញ្ញាតបណ្តោះអាសន្នលេខ ០៦៣/០២ គបប ស្តីពីការបើកបន្ទប់ពិគ្រោះព្យាបាលជំងឺ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៨។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យ៉ុង វ៉ា ទី២ លេខ ០៦៥/០៩ កប/កណ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន យ៉ុង វ៉ា ទី២ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៨៦ កប/អក/វក/លកអ. ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩។

២- លិខិតអញ្ជើញភាគីសហជីពកម្មករនិយោជិតចូលរួមសវនាការ លេខ ០៨៧ កប/អក/វក/លកអ. ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យឯកសារផ្សេងៗ ដែលត្រូវបានដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម

- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ យ៉ុង វ៉ា ទី២ មានកម្មករនិយោជិតសរុបចំនួនប្រហែល ៥០០០ នាក់ (យោងតាមរបាយការណ៍មិនសះជា) ។
- សហជីពកម្មករនិយោជិតមានសមាជិកចំនួនប្រហែល ៣០០ នាក់ ហើយសហជីពនេះ មិនមានភាពជាតំណាងបំផុតនោះទេ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញលើការទាមទារចំណុចវិវាទទី៣ របស់កម្មករនិយោជិត ដោយសុំឱ្យសង់រោងបាយបន្ថែមប្រចាំអាគារទី៣ និង ទី៤ ក្នុងបរិវេណរោងចក្រ យ៉ុង វ៉ា ទី២ ដែលធ្លាប់សន្យាពីមុនមក។
- ភាគីកម្មករនិយោជិតដែលតំណាងដោយសហព័ន្ធសហជីពកម្មករកម្ពុជាអះអាងថា សហជីពមូលដ្ឋានកម្មករនិយោជិត ធ្លាប់មានកិច្ចព្រមព្រៀងមួយជាមួយនិយោជកនៃរោងចក្រ យ៉ុង វ៉ា ទី២ ស្តីពីបញ្ហាសាងសង់រោងបាយបន្ថែមនេះ តែនិយោជកមិនបានគោរពតាមការសន្យានោះទេ។ ហេតុដូច្នេះហើយ ទើបសហជីពកម្មករនិយោជិតបានលើកយកបណ្តឹងនេះមក ដោយទាមទារឱ្យនិយោជកគោរពតាមការសន្យានោះ។
- ភាគីខាងក្រុមហ៊ុនទទួលស្គាល់ថា ការទាមទារឱ្យក្រុមហ៊ុនសាងសង់រោងបាយបន្ថែមនេះ ធ្លាប់បានធ្វើម្តងរួចមកហើយ ប៉ុន្តែក្រុមហ៊ុនពុំមានលទ្ធភាពសាងសង់ជូនបន្ថែមទេ ព្រោះនៅក្នុងក្រុមហ៊ុននេះ មានរោងបាយមួយរួចទៅហើយ។ ចំពោះការព្រមព្រៀងដែលក្រុមហ៊ុនសន្យាថា នឹងសាងសង់ជូននោះ គឺក្រុមហ៊ុនគ្រាន់តែនឹងយកសំណើរនេះទៅពិភាក្សាប៉ុណ្ណោះ តែមិនសន្យាថា ក្រុមហ៊ុននឹងសាងសង់ជូនឡើយ។
- ភាគីសហជីពកម្មករនិយោជិត និងនិយោជកមិនបានផ្តល់ជូននូវកិច្ចព្រមព្រៀង ដែលភាគីទាំងពីរធ្លាប់បានធ្វើមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។
- ភាគីសហជីពបានលើកឡើងថា រោងបាយនេះ មានចំងាយឆ្ងាយធ្វើឱ្យកម្មករនិយោជិតពិបាកធ្វើដំណើរ។
- ចំណែកឯភាគីនិយោជកបានលើកឡើងថា រោងបាយនេះមានចំងាយតែ ៥០ ម៉ែត្រ ប៉ុណ្ណោះ ពីទីតាំងអាគារ ទី២ ទៅអាគារទី៣ និង ទី៤។
- ភាគីសហជីពបានទទួលស្គាល់អំពីរោងបាយដែលមានហើយនោះ ប៉ុន្តែពួកគាត់បានលើកឡើងថា រោងបាយនោះមិនមានទំហំធំគ្រប់គ្រាន់សម្រាប់ដាក់កម្មករនិយោជិតទាំងអស់បាននោះទេ។ រោងបាយនោះអាចដាក់បានសម្រាប់កម្មករនិយោជិតដែលធ្វើការនៅអាគារទី២ ប៉ុណ្ណោះ ចំណែកឯកម្មករនិយោជិតដែលធ្វើការនៅអាគារទី៣ និងអាគារទី៤ មិនអាចទៅប្រជ្រៀតជាមួយកម្មករនិយោជិតដែលធ្វើការនៅអាគារទី២ នោះទេ។ កម្មករនិយោជិតបានបន្ថែមទៀតថា ដល់ពេលម៉ោងសម្រាកពិសារបាយម្តងៗ កម្មករ

និយោជិត ដែលធ្វើការនៅអាគារទី៣ និង ទី៤ នោះ ពុំមានកន្លែងសមរម្យសម្រាប់បរិភោគអាហារទេ ពួកគាត់ខ្លះ បានបង្ខំចិត្តទៅទទួលទាននៅខាងក្រៅរោងចក្រ ខ្លះនៅតាមសំយ៉ាបអាគារ និងខ្លះទៀតនៅតាមមុខបង្គន់ ដែលមានទឹកលិច និងក្លិនស្អុយក៏មានដែរ។

- ភាគីនិយោជកបានលើកឡើងថា ក្រុមហ៊ុនមិនអាចបំពេញតាមសំណើររបស់សហជីពកម្មករនិយោជិតបានទេ ដោយលើកហេតុផលបញ្ជាក់បន្ថែមទៀតថា បច្ចុប្បន្ននេះក្រុមហ៊ុនកំពុងជួបប្រទះបញ្ហាហិរញ្ញវត្ថុ ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក។ ដូចនេះ ក្រុមហ៊ុនពុំមានថវិកាគ្រប់គ្រាន់ ដើម្បីសាងសង់ឡើយ។ ម៉្យាងវិញទៀត នៅក្នុងក្រុមហ៊ុននេះ មានរោងបាយមួយរួចមកហើយ សម្រាប់កម្មករនិយោជិតទទួលទានអាហារ ហើយរោងបាយនេះធំទូលាយ និងមានលក្ខណៈល្អប្រសើរជាងរោងបាយនៃរោងចក្រដទៃ ដោយអាចដាក់កម្មករនិយោជិតបានប្រហែលចំនួន ២០០០ នាក់។

- ប្រការ៨-ចំណុចគ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ ចែងថា" *នៅពេលសម្រាកទទួលទានបាយ កម្មករនិយោជិតទាំងអស់ត្រូវនៅក្រៅពីកន្លែងធ្វើការរបស់ខ្លួន ដើម្បីទទួលទានបាយ គឺនៅអាហារដ្ឋានដែលក្រុមហ៊ុនផ្តល់ជូន ការប្រើប្រាស់បន្ទប់ទឹក បង្គន់ ត្រូវជួយថែរក្សាឱ្យអនាម័យល្អ។*"

**ហេតុផលនៃសេចក្តីសំរេច**

**ចំណុចវិវាទទី ៣ : ភាគីកម្មករនិយោជិត សុំឱ្យក្រុមហ៊ុនសាងសង់រោងបាយជូនបន្ថែមប្រចាំអាគារទី៣ និងទី៤ ក្នុងបរិវេណរោងចក្រ យ៉ុង វ៉ា ២ ដែលបានធ្លាប់សន្យាពីមុនមក**

យោងតាមអង្គហេតុខាងលើ កម្មករនិយោជិតអះអាងថា ក្រុមហ៊ុន យ៉ុង វ៉ា ទី២ មានរោងបាយមួយរួចមកហើយ ប៉ុន្តែរោងបាយមួយនេះមិនមានលក្ខណៈគ្រប់គ្រាន់អាចទទួលចំនួនកម្មករទាំងអស់ដែលធ្វើការនៅរោងចក្រឱ្យពិសារបាយក្នុងពេលតែមួយបានទេ។ ដូចនេះហើយ ទើបកម្មករនិយោជិតបានសុំទាមទារឱ្យក្រុមហ៊ុនសាងសង់រោងបាយមួយបន្ថែមទៀតសម្រាប់កម្មករនិយោជិត ដែលធ្វើការនៅអាគារទី៣ និង ទី៤។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានច្បាប់ និងបទប្បញ្ញត្តិការងារណាតម្រូវឱ្យនិយោជកសង់កន្លែងហូបបាយសម្រាប់កម្មករនិយោជិតទេ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៨/០៤-សោធនីបេ ហេតុផលនៃសេចក្តីសម្រេច ចំណុចទី១ . លេខ ៦០/០៧-ស៊ូត វ៉េ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៨ និង លេខ ៨១/០៧-ស៊ុបព្រីម ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៨ )។

ប៉ុន្តែក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ប្រការ៨-ចំណុចគ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ ចែងថា" *នៅពេលសម្រាកទទួលទានបាយ កម្មករនិយោជិតទាំងអស់*

*ត្រូវនៅក្រៅពីកន្លែងធ្វើការរបស់ខ្លួន ដើម្បីទទួលទានបាយ គឺនៅអាហារដ្ឋានដែលក្រុមហ៊ុនផ្ដល់ជូន ការប្រើប្រាស់បន្ទប់ទឹក បង្គន់ ត្រូវជួយថែរក្សាឱ្យអនាម័យល្អ ។"*

ផ្អែកតាមខ្លឹមសារនៃប្រការ៨ នៃបទបញ្ជាផ្ទៃក្នុងខាងលើនេះ គឺក្រុមហ៊ុនមានកាតព្វកិច្ចសាងសង់នូវរោងបាយសម្រាប់កម្មករនិយោជិតរបស់ខ្លួនសម្រាកហូបបាយ ។

នៅក្នុងសំណុំរឿងនេះ និយោជកបានសាងសង់នូវរោងបាយរួចមកហើយ ប៉ុន្តែកម្មករនិយោជិតទាមទារឱ្យនិយោជកសាងសង់នូវរោងបាយបន្ថែមទៀត ចំពោះអាគារទី៣ និងទី៤ ដោយសាររោងបាយសព្វថ្ងៃមិនអាចទទួលបានកម្មករនិយោជិតទាំងអស់បានទេ ហើយរោងបាយនោះនៅឆ្ងាយ ។ ប៉ុន្តែភាគីនិយោជកបានអះអាងថា រោងបាយនោះមានចំងាយតែ ៥០ម៉ែត្រ ប៉ុណ្ណោះពីអាគារទី៣ និងអាគារទី៤ ហើយរោងបាយនេះមានភាពធំទូលាយ និងមានលក្ខណៈល្អប្រសើរជាងរោងបាយនៃរោងចក្រដទៃ និងអាចដាក់កម្មករនិយោជិតប្រហែលបានចំនួន ២០០០ នាក់ ។

ទន្ទឹមនឹងនេះដែរក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏ពុំបានរកឃើញភស្តុតាងណាដែលបានបញ្ជាក់ពីកិច្ចព្រមព្រៀងដែលតម្រូវឱ្យនិយោជកត្រូវសាងសង់រោងបាយបន្ថែមតាមការអះអាងរបស់កម្មករនិយោជិតនោះដែរ ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ថា ការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនសាងសង់រោងបាយបន្ថែមនេះ វាលើសពីអ្វីដែលជាកាតព្វកិច្ចតាមផ្លូវច្បាប់របស់និយោជក ។ ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្ដាល យល់ឃើញថា ការទាមទាររបស់កម្មករនិយោជិតដែលតំរូវ ឱ្យក្រុមហ៊ុនសាងសង់រោងបាយនោះ គឺ ជាវិវាទអំពីផលប្រយោជន៍ ។

កន្លងមក ចំពោះវិវាទដែលទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលតែងតែពិចារណាថា តើសហជីពដែលនាំវិវាទមកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលនេះមានភាពជាតំណាងបំផុត ដែរ ឬ ទេ ពីព្រោះក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពនេះ ផ្ដល់សមត្ថភាពផ្នែកផ្លូវច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុនមួយ និងសិទ្ធិស្របច្បាប់ក្នុងការនាំវិវាទមកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការដោះស្រាយ ។ (សូមមើលសេចក្ដីបង្គាប់ លេខ ៥៧/០៤-អេវឺហ្គ្រីន ហេតុផលនៃសេចក្ដីសម្រេច ចំណុចវិវាទទី១. លេខ ០៨/០៧-ស៊ាវ គីញ ហេតុផលនៃសេចក្ដីសម្រេច ចំណុចវិវាទទី៣) ។

ដើម្បីទទួលបានភាពជាតំណាងបំផុតនេះ មាត្រា ២៧៧ នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ចែងថា សហជីពត្រូវចុះបញ្ជិកា និងត្រូវបំពេញតាមលក្ខខណ្ឌផ្សេងៗទៀត ដែលមានចែងក្នុងមាត្រានេះ ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានរកឃើញថា សហជីពកម្មករនិយោជិតប្រចាំរោង ចក្រ យ៉ុង វ៉ា ទី២ នេះ មិនមានភាពជាតំណាងបំផុតក្នុងរោងចក្រទេ ។ នៅក្នុងសេចក្ដីបង្គាប់នៃសំណុំរឿងលេខ ០៨/០៧-ស៊ាវ គីញ ហេតុផលនៃសេចក្ដីសម្រេច ចំណុចវិវាទទី៣ បានពន្យល់ថា " *សិទ្ធិនេះជារបស់សហជីពដែលបានចុះបញ្ជិកា ដែលមានសមាជិកច្រើនជាងគេ ហើយបំពេញបានតាមលក្ខណៈវិនិច្ឆ័យឯទៀតដែលមានចែងក្នុងមាត្រា ២៧៧ នៃច្បាប់ស្ដីពីការងារ* " ។ ដូច្នេះ ដើម្បីឱ្យមានភាពស្របគ្នានឹងសំណុំរឿងមុនៗនោះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា សហជីពកម្មករនិយោជិតនេះមិនទាន់មានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការធ្វើជាអ្នក

តំណាងឱ្យកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទដែលទាក់ទងទៅនឹងផលប្រយោជន៍រួមរបស់កម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន យ៉ុង វ៉ា ទី២ នៅឡើយទេ ។

ម៉្យាងវិញទៀត មាត្រា ៤៣ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ បានចែងថា "*សេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលដោះស្រាយវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍ នឹងមកជំនួសអនុសញ្ញារួមសំរាប់រយៈពេលមួយឆ្នាំចាប់ពីថ្ងៃដែលសេចក្ដីបង្គាប់នោះចូលជាស្ថាពរ លើកលែងតែភាគីចរចាបង្កើតអនុសញ្ញារួមមួយ ដើម្បីជំនួសសេចក្ដីបង្គាប់នេះ*" ។

ផ្អែលលើខ្លឹមសារ នៃមាត្រា ៤៣ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ខាងលើ និងសេចក្ដីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ប្រសិនបើក្រុមប្រឹក្សាអាជ្ញាកណ្ដាលចេញសេចក្ដីបង្គាប់លើចំណុចនេះ វានឹងក្លាយជាអនុសញ្ញារួមដែលអនុវត្តទៅលើកម្មករទាំងអស់ក្នុងក្រុមហ៊ុន ហើយធ្វើឱ្យកម្មករនិយោជិតដ៏ទៃទៀត ដែលមិនមែនជាសមាជិកសហជីពនេះ បាត់បង់សិទ្ធិក្នុងការធ្វើកូដកម្ម ដើម្បីទាមទារលើវិវាទ ដែលទាក់ទងនឹងផលប្រយោជន៍នាពេលអនាគត ។ ហេតុដូច្នេះហើយ វានឹងបង្កើតឱ្យមានភាពមិនត្រឹមត្រូវ និងមិនយុត្តិធម៌ សម្រាប់កម្មករនិយោជិតទាំងនោះ ។ (សូមមើលសេចក្ដីបង្គាប់ នៃសំណុំរឿងលេខ ០៦/០៤-ជូស៊ីង ហេតុផលនៃ សេចក្ដីសម្រេច ចំណុចវិវាទទី១, លេខ ០៩/០៥-គីន តាយ ហេតុផលនៃសេចក្ដីសម្រេចចំណុចវិវាទទី២ និងលេខ ៤៨/០៦-ប៊ីល អាប់ ហេតុផលនៃសេចក្ដីសម្រេច ចំណុចវិវាទទី២) ។

សរុបសេចក្ដីមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបដិសេធ ការពិចារណាលើការទាមទាររបស់កម្មករនិយោជិតដែលទាមទារឱ្យក្រុមហ៊ុនសាងសង់រោងបាយបន្ថែមនៅអាគារ ទី៣ និងទី៤ ។

យោងតាមការបង្ហាញពីអង្គហេតុ អង្គច្បាប់ និង ហេតុផល ដូចបានបញ្ជាក់ខាងលើក្រុមប្រឹក្សាអាជ្ញាកណ្ដាល សម្រេចៈ

## សម្រេច និងបង្គាប់

**ចំណុចវិវាទទី ៣ :** បដិសេធការពិចារណាលើការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យក្រុមហ៊ុនសង់រោងបាយបន្ថែមនៅអាគារទី៣ និងទី៤ ។

**ប្រភេទនៃសេចក្ដីបង្គាប់ : សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈិន ភិរម្យ**

ហត្ថលេខា: ----------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អេន ណាន**

ហត្ថលេខា: ----------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **គង់ ផល្លៈ**

ហត្ថលេខា: ----------------------------------